# ព្រឹត្តិបត្រតាមដានវិស័យស្រូវ-អង្ករកម្ពុជា

*យោងតាមទិន្នន័យស្រូវខែវស្សា ឆ្នាំ ២០១៦ និង ខែប្រាំង ឆ្នាំ ២០១៧* *លេខ ១ ខែមីនា ឆ្នាំ ២០១៨*

## ខ្លឹមសារសង្ខេបប្រតិបត្តិ

**ការរៀបរៀងគោលនយោបាយស្រូវអង្ករ បានបង្ហាញពីភាពចាំបាច់ នៃការងារតាមដានការវិវត្តន៍វិស័យស្រូវអង្ករនៅប្រទេសកម្ពុជា ដោយយោងទៅតាមពត៌មានថ្មីៗ និងជាក់លាក់។ ពត៌មាននៅថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ អំពីទីផ្សារនៃជាតុចូល និងជាតុចេញរបស់ ផលិតកម្មស្រូវអង្ករ ពិតជាមានសារៈសំខាន់សម្រាប់ការតាមដាន និងវាយតម្លៃអំពីលទ្ធផល នៃការសម្រេចលើគោលនយោបាយស្រូវអង្ករ។**

ការមានពត៌មានអំពីចំណូល និងចំណាយរបស់ភ្នាក់ងារនីមួយៗ នៅតាមខ្សែច្រវាក់តម្លៃហើយជាពត៌មានដែលត្រូវបានភាគីពាក់ព័ន្ធទទួលស្គាល់គឺជាតម្រូវការមូលដ្ឋានសម្រាប់ការបង្កើតគោលនយោបាយស្រូវអង្កររួមរបស់ភាគីឯកជន និងភាគីសាធារណៈរបស់វិស័យស្រូវអង្ករដែលប្រឈមនឹងបញ្ហានានា។ ហេតុដូច្នេះការអង្កេតលក្ខណៈសេដ្ឋកិច្ចនៃវិស័យស្រូវអង្កររបស់ប្រទេសកម្ពុជាត្រូវបានបង្កើតឡើងដើម្បីបំរើ ជាឧបករណ៍សម្រាប់ការពិភាក្សាគោលនយោបាយក្នុងចំណោមអ្នកបង្កើតគោលនយោបាយ និងភាគីពាក់ព័ន្ធក្នុងវិស័យស្រូវអង្កររបស់កម្ពុជា។

ប្រព័ន្ធ ឬ ម៉ូដែលខ្សែច្រវាក់តម្លៃស្រូវអង្ករចំនួន ១៣ ដែលជាតំណាងឱ្យប្រព័ន្ធខ្សែច្រវាក់តម្លៃស្រូវអង្ករនៅប្រទេសកម្ពុជា ត្រូវបានបង្កើតដោយអ្នកស្រាវជ្រាវព្រឹត្តិបត្រនេះ ដោយបូកបញ្ចូលតួនាទីផ្សេងៗ របស់ភ្នាក់ងារនីមួយៗក្នុងខ្សែច្រវាក់តម្លៃស្រូវអង្ករដូចជាៈ កសិករផលិតស្រូវឈ្មួញប្រមូលទិញស្រូវរោងម៉ាស៊ីនកិនស្រូវ និងឈ្មួញលក់អង្ករ។

ប្រព័ន្ធ ឬ ម៉ូដែលខ្សែច្រវាក់តម្លៃស្រូវអង្ករចំនួន ១៣ រួមមានខ្សែច្រវាក់ តម្លៃស្រូវអង្កររដូវវស្សាដែលជាពូជក្រអូប និងប្រកាន់រដូវខ្សែច្រវាក់ តម្លៃស្រូវអង្កររដូវវស្សាដែលជាពូជមិនក្រអូប ខ្សែច្រវាក់តម្លៃស្រូវអង្ករ ដើមរដូវវស្សាដែលជាពូជមិនក្រអូបខ្សែច្រវាក់តម្លៃស្រូវអង្ករ រដូវប្រាំង ដែលជាពូជក្រអូប និងខ្សែច្រវាក់តម្លៃស្រូវអង្កររដូវប្រាំងដែលជាមិនក្រអូប។ ការសិក្សានេះមានខ្សែច្រវាក់តម្លៃស្រូវអង្កររដូវវស្សា ដែលជាពូជក្រអូប និងប្រកាន់រដូវចំនួន ៤ ខ្សែច្រវាក់តម្លៃស្រូវអង្កររដូវវស្សា ដែលជាពូជមិនក្រអូបចំនួយ ៣ ខ្សែច្រវាក់តម្លៃស្រូវអង្ករ ដើមរដូវវស្សាដែលជាពូជមិនក្រអូបចំនួន ១ ខ្សែច្រវាក់តម្លៃស្រូវអង្ករ រដូវប្រាំង ដែលជាពូជក្រអូបចំនួន ៣ និងខ្សែច្រវាក់តម្លៃស្រូវអង្កររដូវប្រាំង ដែលជាមិនក្រអូបចំនួន ២។

## លទ្ធផលនៃការវិភាគ

- **លទ្ធផលនៃផលិតកម្មស្រូវរបស់កសិករ** ការដាំដុះស្រូវក្នុងដី ១ ហិកតា ត្រូវការចំណាយពី ១.៤១ លាន រៀល ទៅ ២.៨២ លានរៀល។ ក្នុងចំណោមការចំណាយទាំងអស់នៃ ការផលិតស្រូវការចំណាយលើដី និងថ្នាំគីមីការជួលសេវាកម្មនានា (ម៉ាស៊ីន និងពលកម្ម) និងគ្រាប់ពូជគឺជាខ្ទង់ចំណាយធំជាងគេទាំង ៣។ ក្នុងដី ១ ហិកតា កសិករអាចទទួលបានប្រាក់ចំណេញពី ៥៤២០០០ រៀល ទៅ ៩៣១០០០ រៀល ឯកំរៃពេលកម្មគ្រួសារពីការធ្វើស្រែអាចទទួលបានពី ២១២០០ រៀល ទៅ ៤២០០០រៀល ក្នុងមួយថ្ងៃ។ ជាសម្គាល់ការផលិតស្រូវមិនក្រអូបនៅរដូវប្រាំង និងដើមរដូវវស្សា ត្រូវការការប្រើប្រាស់ដី និងថ្នាំគីមីច្រើនដែលអាចធ្វើឱ្យមានផលប៉ះពាល់ទៅលើសុខភាពរបស់កសិករអ្នកបរិភោគ និងបរិស្ថាន។
- **លទ្ធផលនៃការផលិតអង្កររបស់រោងម៉ាស៊ីនកិនស្រូវ** ដើម្បីកិនឱ្យបានអង្ករ ១តោន រោងម៉ាស៊ីនកិនស្រូវត្រូវចំណាយចាំពី ១៨៥០០០ រៀល ទៅ ៣៧០០០០ រៀល។ ចំណាយលើការរំលោះ សម្ភារៈបរិក្ខារ ថាមពល (អគ្គិសនី) និងហិរញ្ញវត្ថុគឺជាចំណាយធំៗ ជាងគេទាំង ៣ របស់រោងម៉ាស៊ីនកិនស្រូវ។ ទិន្នផលពីការវិនិយោគប្រាក់អាចទទួលបានពី ១.៨ % ទៅ ១៣.៩%។
- **លទ្ធផលនៃផលិតកម្មស្រូវរបស់កសិករ** ការដាំដុះស្រូវក្នុងដី ១ ហិកតា ត្រូវការចំណាយពី ១.៤១ លាន រៀល ទៅ ២.៨២ លានរៀល។ ក្នុងចំណោមការចំណាយទាំងអស់ នៃការផលិតស្រូវការ

### មាតិកា

**១. សេចក្តីផ្តើម** ....................................................២
**២. ការវិភាគ** ....................................................៤
២.១ ការវាយតម្លៃលើការអនុវត្តរបស់កសិករ ..................៤
២.២ ការវាយតម្លៃលើការអនុវត្តរបស់រោងម៉ាស៊ីនកិនស្រូវ ....៥
២.៣ ការវាយតម្លៃលើខ្សែច្រវាក់តម្លៃស្រូវអង្ករ .................៦
២.៤ ឥទ្ធិពលរបស់កត្តាផ្សេងៗទៅលើផលទទួលបានពីការវិនិយោគ....................................................៩
២.៥ ភាពចំណេញរបស់រោងម៉ាស៊ីនកិនស្រូវ ...............១០
**៣. សរុបសេចក្តីនិងអនុសាសន៍** ............................១២

ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
Supreme National Economic Council

*ព្រឹត្តិប័ត្រនេះរៀបរៀងដោយ លោក **ឡាកន ហ្វ្រេដឺរិក** នៃមជ្ឈមណ្ឌលស្រាវជ្រាវអន្តរជាតិបារាំងសម្រាប់ការអភិវឌ្ឍកសិកម្ម, លោក **ច័ន្ទ សុផល** នៃមជ្ឈមណ្ឌលសិក្សាគោលនយោបាយ និង លោក **គីម មិនា** នៃមជ្ឈមណ្ឌលសិក្សាគោលនយោបាយ*

AFD

ចំណាយលើជី និងថ្នាំគីមីការជួលសេវាកម្មនានា (ម៉ាស៊ីន និងពលកម្ម) និងគ្រាប់ពូជគឺជាខ្ទង់ចំណាយធំជាងគេទាំង ៣។ ក្នុងដី ១ ហិកតា កសិករអាចទទួលបានប្រាក់ចំណេញពី ៥៤២០០០ រៀល ទៅ ៩៣១០០០ រៀលឯកំរៃពេលកម្មគ្រួសារពីការធ្វើស្រែអាចទទួលបានពី ២១២០០ រៀល ទៅ ៤២០០០រៀល ក្នុងមួយថ្ងៃ។ ជាសម្គាល់ការផលិតស្រូវមិនក្រអូបនៅរដូវប្រាំង និងដើមរដូវវស្សា ត្រូវការការប្រើប្រាស់ជី និងថ្នាំគីមីច្រើនដែលអាចធ្វើឱ្យមានផលប៉ះពាល់ទៅលើសុខភាពរបស់កសិករអ្នកបរិភោគ និងបរិស្ថាន។

• **លទ្ធផលនៃខ្សែច្រវាក់តម្លៃផលិតកម្មស្រូវអង្ករ** ជាមធ្យមកម្ពុជាអាចទទួលបានតម្លៃបន្ថែមពី ១០៧ ដុល្លារ ទៅ ៤០៨ ដុល្លារ ពីការផលិតអង្ករ ១ តោន (រាប់ពីចាប់ពីការផលិតស្រូវ រហូតដល់លក់អង្ករ)។ ការដាំដុះស្រូវទទួលបានតម្លៃបន្ថែមប្រហែល ៥០ នៃតម្លៃបន្ថែមសរុបរបស់ខ្សែច្រវាក់តម្លៃផលិកម្មស្រូវអង្ករ។ ការ ៥០ នៃតម្លៃបន្ថែមសរុបរបស់ខ្សែច្រវាក់តម្លៃផលិកម្មស្រូវអង្ករ។ ការវិភាគរបស់យើងក៏រកឃើញថា ភាគរយតម្លៃបន្ថែមរបស់កសិករនឹងកើនឡើង បើតម្លៃបន្ថែមសរុបរបស់ខ្សែច្រវាក់តម្លៃផលិកម្មស្រូវអង្ករកាន់តែកើនខ្ពស់។ ចំពោះចំណែកផ្សេងទៀតនៃតម្លៃបន្ថែមសរុបនេះ ឈ្មួញប្រមូលទិញស្រូវទទួលបាន ៩% រោងម៉ាស៊ីនទទួលបាន ២៣% និងឈ្មួញលក់អង្ករទទួលបាន ១៨%។

ការវិភាគរបស់យើងបានបង្ហាញថាប្រព័ន្ធស្រូវអង្ករដែលបង្កើតតម្លៃបន្ថែមបានខ្ពស់ជាងគេគឺប្រព័ន្ធស្រូវអង្ករក្រអូបនៅរដូវប្រាំង និងរដូវវស្សាដែលកសិករមានម៉ាស៊ីនភ្ជួរដីប្រើប្រាស់ខ្លួនឯង។ ប្រព័ន្ធទាំងនេះក៏ត្រូវបានដំណើរការដោយរោងម៉ាស៊ីនធំៗដែលមានសមត្ថភាពកិនស្រូវក្នុងបរិមាណ ១០ តោន ក្នុង ១ម៉ោង ហើយជាប្រព័ន្ធដែលអង្ករក្រអូប ត្រូវបាននាំចេញទៅកាន់ទីផ្សារអន្តរជាតិ។ ការវិភាគនេះក៏បង្ហាញថាប្រព័ន្ធស្រូវមិនក្រអូបនៅដើមរដូវវស្សា និងប្រព័ន្ធស្រូវក្រអូបរដូវប្រាំង ដែលភាគច្រើនគ្រាន់តែនាំចេញស្រូវសើម ទៅប្រទេសផ្សេងទទួលបានផលចំណេញតិចតួចជាងគេ។

## អនុសាសន៍

• **បន្ថយការថ្លៃជីនិងថ្នាំគីមី** យោងទៅតាមកម្រិតតម្លៃនាពេលបច្ចុប្បន្ននេះជី និងថ្នាំគីមីការជួល សេវាកម្មនានា (ឧទាហរណ៍ជួលម៉ាស៊ីន) និងគ្រាប់ពូជគឺជាកត្តាសំខាន់ៗ ដែលកំណត់ភាពចំណេញរបស់កសិករ។ ដើម្បីបន្ថយថ្លៃជី និងថ្នាំកសិកម្មព្រឹត្តិប័ត្រនេះសំណូមពររដ្ឋាភិបាលគួរពិចារណា លើះ ១) បង្កើនអន្តរាគមន៍ដែលជួយបន្ថយថ្លៃថ្នាំ និងជីគីមីជាមួយ និងសកម្មភាពផ្សព្វផ្សាយកសិកម្មនានាដល់កសិករដោយផ្តោតលើការប្រើប្រាស់ជី និងថ្នាំគីមីតាមក្បួនខ្នាតឱ្យមានប្រសិទ្ធភាព និងចំណាយតិច និង ២) ជំរុញឱ្យមានដាំដុះបែបការអនុវត្តន៍កសិកម្មល្អ និងការដាំដុះស្រូវដោយមាននិរន្តរភាពសម្រាប់កសិករក្នុងការ ផ្គត់ផ្គង់ទៅទីផ្សារពិសេសៗដែលអាចទទួលបានតម្លៃបន្ថែមខ្ពស់។

• **ប្រើប្រាស់សមត្ថភាពម៉ាស៊ីនកិននិងឃ្លាំងស្រូវកុំឱ្យសល់ទំនេរច្រើន** ការកិនស្រូវទទួលបានជាមធ្យមប្រមាណ ២៣% នៃតម្លៃបន្ថែមសរុប។ ការធ្វើឱ្យមានការប្រើប្រាស់សមត្ថភាពម៉ាស៊ីនកិន និងឃ្លាំងស្រូវឱ្យបានយ៉ាងតិច ៣០% នៃសមត្ថភាពកិនស្រូវសរុបគឺជាគន្លឹះនៃភាពចំណេញរបស់រោងម៉ាស៊ីនកិនស្រូវ និងភាពប្រកួតប្រជែងរបស់ខ្សែច្រវាក់តម្លៃផលិតកម្មស្រូវអង្ករ។ ដើម្បីជំរុញឱ្យរោងម៉ាស៊ីនកិនស្រូវប្រើប្រាស់ជាអតិបរមានូវសមត្ថភាពម៉ាស៊ីនកិន និងឃ្លាំងស្រូវព្រឹត្តិប័ត្រនេះសំណូមពរឱ្យរដ្ឋាភិបាលពិចារណាលើការបង្កើនកម្ចីទៅឱ្យរោងម៉ាស៊ីនកិនស្រូវ និងធ្វើឱ្យប្រសើរឡើងនូវការផ្គត់ផ្គង់អគ្គិសនី។ ជាមួយនឹងហានិភ័យនៃការបាត់បង់លក្ខខ័ណ្ឌអំណោយផលពិសេសក្នុងការនាំចេញទៅទីផ្សារអឺរ៉ុបការធ្វើពិពិធកម្មទីផ្សារនាំចេញគួរជាអាទិភាពមួយនៃវិស័យស្រូវអង្កររបស់កម្ពុជា។

## ១. សេចក្តីផ្តើម

ការវិភាគប្រព័ន្ធខ្សែច្រវាក់តម្លៃស្រូវអង្ករ ត្រូវបានធ្វើឡើងដោយយោងទៅតាមខ្ទង់ថវិកាតំណាង ដែលត្រូវបានបង្កើតឡើងសម្រាប់ភ្នាក់ងារនីមួយៗ និងសម្រាប់ប្រព័ន្ធខ្សែច្រវាក់តម្លៃតាមផ្នែកនីមួយៗ។ ខ្ទង់ចំណាយចំណូលតំណាងទាំងនេះ បង្ហាញពីចំណាយលម្អិតការបែងចែកតម្លៃបន្ថែម និងសូចនាករមួយចំនួន ដូចជាប្រាក់ចំណាយ (Cost) ប្រាក់ចំណេញ (Profit) តម្លៃបន្ថែម (Added Value) ទិន្នផល នៃមូលធន (Return to Capital) និងទិន្នផលនៃការវិនិយោគ (Return to Investment) ការវិភាគពីភាពប្រែប្រួល (Sensitivity Analysis) របស់សូចនាករសំខាន់ៗមួយចំនួនក៏ត្រូវបានលើកឡើង នៅក្នុងព្រឹត្តិប័ត្រនេះផងដែរ ដើម្បីវាយតម្លៃពីទំនាក់ទំនងរវាងកត្តាសំខាន់ៗមួយចំនួនទៅនឹងប្រាក់ចំណេញ និងភាគរយនៃចំណែកតម្លៃបន្ថែម។ ការវិភាគនេះ មានសារៈប្រយោជន៍សម្រាប់អ្នកសម្រេចលើគោលនយោបាយ ដើម្បីឱ្យពួកគាត់ផ្តោតទៅលើយន្តការដែលមានទិន្នផលខ្ពស់។

ប្រព័ន្ធខ្សែច្រវាក់តម្លៃស្រូវអង្ករ ចំនួន ១៣ ត្រូវបានបង្កើតឡើងដោយការបញ្ចូលគ្នានូវសកម្មភាពរបស់ភ្នាក់ងារពាក់ព័ន្ធ ដូចជាការផលិតស្រូវការប្រមូលទិញស្រូវការកិនស្រូវ និងការលក់រាយអង្ករ។ ប្រព័ន្ធខ្សែច្រវាក់តម្លៃស្រូវអង្ករទាំងនេះ គឺជាតំណាងឱ្យខ្សែច្រវាក់តម្លៃស្រូវអង្កររដូវវស្សាដែលជាពូជក្រអូប និងប្រកាន់រដូវខ្សែច្រវាក់

តម្លៃស្រូវអង្កររដូវវស្សា ដែលជាពូជមិនក្រអូប ខ្សែច្រវាក់តម្លៃស្រូវអង្ករដើមរដូវវស្សាដែលជាពូជមិនក្រអូប ខ្សែច្រវាក់តម្លៃស្រូវអង្ករ រដូវប្រាំង ដែលជាពូជក្រអូប និងខ្សែច្រវាក់តម្លៃស្រូវអង្កររដូវប្រាំង ដែលជាពូជមិនក្រអូប។

ក្រាបទី១:ប្រព័ន្ធស្រូវអង្កររដូវវស្សា




ក្រាបទី២: ប្រព័ន្ធស្រូវអង្កររដូវប្រាំង



# ២. ការវិភាគ

## ២.១. ការវាយតម្លៃលើការអនុវត្តរបស់កសិករ

### ២.១.១. ថ្លៃដើមសម្រាប់ការផលិតស្រូវ

ការវិភាគបានបង្ហាញថាថ្លៃដើមសរុបលើការផលិតស្រូវ មានទំហំចាប់ពី ១.៤១ លានរៀល ដល់ ២.៨២ លានរៀល ក្នុង ១ ហិកតា។ ជាមធ្យមចំណាយលើការផលិតស្រូវសរុបមានទំហំប្រមាណ ១.៨៨ លានរៀល ក្នុង ១ ហិកតា។ ការចំណាយលើសេវាកម្ម [១] ជី និងថ្នាំ គីមី [២] និងពូជស្រូវគឺជាការចំណាយធំជាងគេទាំង ៣ របស់ការផលិតស្រូវសម្រាប់គ្រប់ប្រព័ន្ធផលិតស្រូវទាំងអស់ (**មើលក្រាបទី៣**)។

ក្រាបទី៣: ភាគរយនៃខ្ទង់ចំណាយនីមួយៗក្នុងការផលិតស្រូវ (%)




ប្រភព៖ ការគណនារបស់អ្នកនិពន្ធ

### ២.១.២. ប្រាក់ចំណេញ

**ក្រាបទី៤**: បង្ហាញថា ប្រាក់ចំណេញរបស់កសិករពីការផលិតស្រូវ មានទំហំចាប់ពី ៥៤២០០០ រៀល ទៅ ៩៣១០០០ រៀល ក្នុង ១ហិកតា ដោយមិនគិតពីថ្លៃឈ្នួលដី។ ជាមធ្យមថ្លៃឈ្នួលដីមានតម្លៃប្រហែល ៤០០០០០ រៀល សម្រាប់ការជួលដី ១ ហិកតា ក្នុង ១ រដូវ។ ការវិភាគបានបង្ហាញថា កសិករដែលផលិតប្រភេទពូជស្រូវមិនក្រអូបនៅដើមរដូវវស្សា និងមានម៉ាស៊ីន (**ក្រាបទី៣**) អាចរកបានប្រាក់ចំណេញច្រើនជាងគេពីដី ១ ហិកតា ប្រៀបធៀបទៅនឹងប្រព័ន្ធផលិតស្រូវដទៃ។ ប៉ុន្តែប្រព័ន្ធនេះមានការប្រើប្រាស់ជី និងថ្នាំកសិកម្មច្រើនជាងគេ។

ក្រាបទី៤: ប្រាក់ចំណេញរបស់កសិករក្នុង ១ ហិកតាដី (លានរៀលក្នុង ១ ហិកតា)




ប្រភព៖ ការគណនារបស់ក្រុមអ្នកស្រាវជ្រាវ

| ចំនាំ: | WS: រដូវវស្សា DS: រដូវប្រាំង | NF: មិនក្រអូប UF: ក្រអូប | OM: មានម៉ាស៊ីន |
|---|---|---|---|
| | EWS: ដើមរដូវវស្សា | PF: ក្រអូបប្រកាន់រដូវ | RM: ជួលម៉ាស៊ីន |

១. ចំណាយសេវាកម្មមានដូចជាការងាររៀបចំដីគ្រប់គ្រងដំណាំច្រូតកាត់ជួសជុលថែទាំគោយន្តឬត្រាក់ទ័រជួសជុលថែទាំម៉ាស៊ីនប៉ូមទឹក និងសេវាបូមទឹក។

២. ជី និងថ្នាំគីមីមានជីកសិកម្មថ្នាំសម្លាប់សត្វល្អិត និងថ្នាំសម្លាប់ស្មៅ។

### ២.១.៣. កំរៃពលកម្មគ្រួសារទទួលបានពីការធ្វើស្រែ

ជាមធ្យមកសិករបានប្រើប្រាស់កម្លាំងគ្រួសារសរុបប្រមាណ ២៣ ថ្ងៃ សម្រាប់ដីស្រែ ១ ហិកតា។ ការប្រើប្រាស់កម្លាំងគ្រួសារសម្រាប់ប្រព័ន្ធដំណាំស្រូវរដូវវស្សាមានប្រមាណ ២០ ថ្ងៃ សម្រាប់ប្រព័ន្ធដំណាំស្រូវ ដើមរដូវវស្សាមានប្រមាណ ២៤ ថ្ងៃ និងសម្រាប់ប្រព័ន្ធដំណាំស្រូវរដូវប្រាំងមានប្រមាណ ២៧ ថ្ងៃ។ ជាមធ្យមកសិករធ្វើស្រែដែលមានដីរកបានកំរៃពលកម្មគ្រួសារទទួលបានពីការធ្វើស្រែចំនួន ២៩៣០០ រៀល ក្នុង ១ ថ្ងៃ ពីដី ១ ហិកតា។ **ក្រាបទី៥**: ប្រព័ន្ធដំណាំស្រូវ ក្រអូបរដូវវស្សាគឺជាប្រព័ន្ធដែលផ្តល់កំរៃពលកម្មគ្រួសារទទួលបានពីការធ្វើស្រែខ្ពស់ជាងគេដែលមានទំហំប្រមាណ ៤២០០០ រៀល ក្នុង ១ ថ្ងៃ។ បន្ទាប់ពីប្រព័ន្ធដំណាំនេះ ប្រព័ន្ធដំណាំដែលផ្តល់កំរៃ ពលកម្មគ្រួសារទទួលបានពីការធ្វើស្រែខ្ពស់គឺ**ក្រាបទី៣**: ប្រព័ន្ធដំណាំស្រូវមិនក្រអូបដើមរដូវវស្សា និងក្រាបទី១: ប្រព័ន្ធដំណាំស្រូវមិនក្រអូបរដូវវស្សា។ ប្រព័ន្ធដំណាំដែលផ្តល់កំរៃ ពលកម្មគ្រួសារទទួលបានពីការធ្វើស្រែទាបជាងគេគឺក្រាបទី៤: ប្រព័ន្ធដំណាំស្រូវមិនក្រអូបរដូវប្រាំង ដែលមានប្រាក់ចំណូលទទួលបានពីពលកម្មគ្រួសារប្រមាណ ២១២០០ រៀល ក្នុង ១ថ្ងៃ ( សូមមើលក្រាបទី៥ )។

**ក្រាបទី៥: កំរៃពលកម្មគ្រួសារពីការធ្វើស្រែ (ពាន់រៀល/ថ្ងៃ)**




ប្រភព៖ ការគណនារបស់ក្រុមអ្នកស្រាវជ្រាវ

ចំនាំ: WS: រដូវវស្សាDS: រដូវប្រាំង NF: មិនក្រអូបF: ក្រអូប OM: មានម៉ាស៊ីន
EWS: ដើមរដូវវស្សា PF:ក្រអូបប្រកាន់រដូវ RM: ជួលម៉ាស៊ីន

## ២.២. ការវាយតម្លៃលើការអនុវត្តរបស់រោងម៉ាស៊ីនកិនស្រូវ

### ២.២.១. ចំណាយសម្រាប់ការកិនស្រូវ

ចំណាយសរុបលើការកិនស្រូវមានទំហំចាប់ពី ១៨៥០០០ រៀល ដល់ ៣៧០០០០ រៀល ក្នុង ១ ហិកតា ហើយជាមធ្យមមានទំហំ ២២៨០០០ រៀល សម្រាប់ផលិតឱ្យបាន ១ តោន អង្ករ។ ចំណាយសរុបនេះ គឺមិនបានរាប់បញ្ចូលចំណាយទិញស្រូវចូលសម្រាប់កិនទៅជាអង្ករនោះទេ។

ថ្លៃចំណាយលើទ្រព្យមិនសកម្ម [៣] ថ្លៃចំណាយលើថាមពល [៤] និងថ្លៃចំណាយលើហិរញ្ញវត្ថុគឺជាខ្ទង់ចំណាយដែលខ្ពស់ជាងគេ នៃការចំណាយនេះរបស់ប្រព័ន្ធកិនស្រូវតំណាងទាំងអស់។ ជាមធ្យមថ្លៃចំណាយលើទ្រព្យមិនសកម្មមានទំហំ ៨៩០០០ រៀល ( ៣២.៦% ) ថ្លៃចំណាយលើថាមពលមានទំហំ ៥១០០០ រៀល ( ១៨.៨% ) និងថ្លៃចំណាយលើហិរញ្ញវត្ថុមានទំហំ ៣២០០០ រៀល ( ១១.៨% ) សម្រាប់កិនអង្ករឱ្យបាន ១ តោន ( **សូមមើលក្រាបទី៦** )។ ដូច្នេះអ្នករៀបរៀងគោលនយោបាយ និងភាគីពាក់ព័ន្ធ គួរពិភាក្សាពីយន្តការនានាដើម្បីជួយកាត់បន្ថយ លើថ្លៃចំណាយលើទ្រព្យមិនសកម្មថ្លៃចំណាយលើថាមពល និងថ្លៃចំណាយលើហិរញ្ញវត្ថុរបស់រោងម៉ាស៊ីនកិនស្រូវ។

**ក្រាបទី៦: ភាគរយនៃខ្ទង់ចំណាយសម្រាប់ការកិនស្រូវ (%)**




ប្រភព៖ ការគណនារបស់ក្រុមអ្នកស្រាវជ្រាវ

៣. ចំណាយទ្រព្យមិនសកម្មសំដៅទៅលើថ្លៃរំលោះនៃបរិក្ខាកិនស្រូវដូចជាម៉ាស៊ីនកិនស្រូវម៉ាស៊ីនបែងចែកអង្ករម៉ាស៊ីនវេចខ្ចប់ឃ្លាំងរោងម៉ាស៊ីន និងគ្រឿងយន្តលើកទំនិញ។
៤. ចំណាយថាមពលមានដូចជាអគ្គិសនីសម្រាប់កិនស្រូវសម្ងួតស្រូវនិងបែងចែកអង្ករ និងម៉ាសូតសម្រាប់គ្រឿងយន្តលើកទំនិញ។

### ២.២.២. ទិន្នផលមូលធន

**ក្រាបទី៧**: បង្ហាញពីពត៌មាននៃទិន្នផលមូលធន ( Return to Capital ) របស់រោងម៉ាស៊ីន សម្រាប់ប្រព័ន្ធនីមួយៗ។ ទិន្នផលមូលធន មានទំហំចាប់ពី ១.៨ % ទៅ ១៣.៩ % និងជាមធ្យមមានទំហំ ៨.១ % ។

**ក្រាបទី៧: ផលទទួលបានពីមូលធនសម្រាប់ប្រព័ន្ធកិនស្រូវនីមួយៗ (%)**




ប្រភព៖ ការគណនារបស់ក្រុមអ្នកស្រាវជ្រាវ

ចំនាំ: WS: រដូវវស្សា NF: មិនក្រអូប F: ក្រអូប 1T: 1-តោន UM: ទីផ្សារក្នុងស្រុក
DS: រដូវប្រាំង PF:ក្រអូបប្រកាន់រដូវ 10T: 10-តោន EX: ទីផ្សារនាំចេញ

## ២.៣. ការវាយតម្លៃលើខ្សែច្រវាក់តម្លៃស្រូវអង្ករ

### ២.៣.១. ការចំណាយ

ខ្ទង់ចំណាយរបស់ប្រព័ន្ធខ្សែច្រវាក់តម្លៃស្រូវអង្ករនីមួយៗ ត្រូវបានបង្ហាញជាភាគរយនៅ **ក្រាបទី ៨** ដោយមិនគិតពីថ្លៃស្រូវ។ ចំណាយលើសេវាកម្ម[៥] ចំណាយលើជី និងថ្នាំគីមី និងចំណាយលើពូជស្រូវ គឺជាខ្ទង់ចំណាយដែលខ្ពស់ជាងគេទាំង ៣ នៅក្នុងប្រព័ន្ធខ្សែច្រវាក់តម្លៃស្រូវអង្ករ។ ជាមធ្យមចំណាយលើសេវាកម្មត្រូវជា ២៩% ចំណាយលើជី និងថ្នាំគីមីត្រូវជា ១៨% និងចំណាយលើពូជស្រូវត្រូវជា ១១% នៃចំណាយសរុប។

**ក្រាបទី៨: ភាគរយនៃខ្ទង់ចំណាយនីមួយៗរបស់ខ្សែច្រវាក់តម្លៃស្រូវអង្ករ (%)**




ប្រភព៖ ការគណនារបស់ក្រុមអ្នកស្រាវជ្រាវ

### ២.៣.២. តម្លៃបន្ថែម

ភាគរយតម្លៃបន្ថែមដែលភ្នាក់ងារនីមួយៗនៅតាមខ្សែច្រវាក់តម្លៃស្រូវអង្ករទទួលបានត្រូវបានបង្ហាញនៅ**ក្រាបទី ៩**។ តម្លៃបន្ថែមរបស់ប្រព័ន្ធខ្សែច្រវាក់តម្លៃស្រូវអង្ករមានទំហំពី ១០៧ ដុល្លារ ទៅ ៤០៨ ដុល្លារ សម្រាប់ការផលិតអង្ករបាន ១តោន។ ជាមធ្យម តម្លៃបន្ថែមសម្រាប់ការផលិតអង្ករ ១ តោន មានទំហំ ២៦៦ ដុល្លារ។ ជាមធ្យមកសិករទទួលបានតម្លៃបន្ថែម ៥០% នៃតម្លៃបន្ថែមសរុប។ ជាបន្ទាប់រោងម៉ាស៊ីនកិនស្រូវទទួលបានតម្លៃបន្ថែមជាមធ្យម ២៣% នៃតម្លៃបន្ថែមសរុប។ មានការជជែកពិភាក្សាជាច្រើនអំពីតម្លៃបន្ថែម ដែលត្រូវបានឈ្មួញប្រមូលទិញស្រូវទាញយកតែការសិក្សារបស់យើងរកឃើញថា ឈ្មួញប្រមូលទិញស្រូវទទួលបានតែ ៩ ប៉ុណ្ណោះនៃតម្លៃបន្ថែមសរុបពីការផលិតអង្ករ ១ តោន។

**ក្រាបទី៩: ភាគរយនៃតម្លៃបន្ថែមដែលភ្នាក់ងារនីមួយៗទទួលបាន (%)**




ប្រភព៖ ការគណនារបស់ក្រុមអ្នកស្រាវជ្រាវ

**ក្រាបទី១០:** បង្ហាញពីទំនាក់ទំនងនៃចំណែកតម្លៃបន្ថែម ដែលបង្កើតដោយប្រព័ន្ធខ្សែច្រវាក់តម្លៃស្រូវអង្ករ។ ទំងន់នៃប្រព័ន្ធខ្សែច្រវាក់តម្លៃស្រូវអង្ករទាំងនេះ ត្រូវបានប៉ាន់ប្រមាណដោយយោងទៅតាមទិន្នន័យ ពីផលិតកម្មរបស់ ប្រព័ន្ធខ្សែច្រវាក់តម្លៃស្រូវអង្ករតម្រូវការអង្ករក្នុងស្រុកការនាំចេញអង្ករ និងការនាំចេញស្រូវ។ ប្រភេទស្រូវអង្កររដូវវស្សា សម្រាប់ទីផ្សារក្នុងស្រុក តំណាងឱ្យតម្លៃបន្ថែមប្រមាណ ៧០% នៃតម្លៃបន្ថែមសរុប ដែលបង្កើតដោយប្រព័ន្ធខ្សែច្រវាក់តម្លៃស្រូវអង្ករទាំង ១៣។ ប្រព័ន្ធខ្សែច្រវាក់តម្លៃស្រូវអង្ករ សម្រាប់ទីផ្សារនាំចេញ (មានទាំងការនាំចេញស្រូវ និងការនាំចេញអង្ករ) បង្កើតប្រហែល ២២% នៃតម្លៃបន្ថែមសរុប។

**ក្រាបទី១០: ចំណែកនៃតម្លៃបន្ថែមដែលបង្កើតដោយខ្សែច្រវាក់តម្លៃស្រូវអង្ករ**



ប្រភព៖ ការគណនារបស់ក្រុមអ្នកស្រាវជ្រាវ

ចំនាំ: ■ រដូវវស្សាមិនក្រអូប ■ រដូវវស្សាក្រអូបប្រកាន់រដូវ ■ ដើមរដូវវស្សា ■ រដូវប្រាំងមិនក្រអូប ■ រដូវប្រាំងក្រអូប

**ក្រាបទី១១:** បង្ហាញពីទំនាក់ទំនងរវាងតម្លៃបន្ថែមក្នុងការផលិតអង្ករ ១ តោន ដែលបង្កើតដោយប្រព័ន្ធខ្សែច្រវាក់តម្លៃស្រូវអង្ករនីមួយៗ និងប្រាក់ចំណេញរបស់កសិករសម្រាប់ការចូលរួមក្នុងការផលិតអង្ករ ១តោន នេះ។ **ក្រាបទី១១:** បង្ហាញថាប្រាក់ចំណេញរបស់កសិករមានទំនាក់ទំនងជាវិជ្ជមានជាមួយនឹងតម្លៃបន្ថែមដែលប្រព័ន្ធខ្សែច្រវាក់តម្លៃស្រូវអង្ករបង្កើតបាន។ ទំនាក់ទំនងនេះមានផលល្អចំពោះកសិករព្រោះកសិករនឹងទទួលបានផលប្រយោជន៍ច្រើនពីការកើនឡើងនៃតម្លៃបន្ថែមដែលអាចបានមកពីការឡើងថ្លៃនៃអង្ករនៅទីផ្សារអន្តរជាតិ។

**ក្រាបទី១១: តម្លៃបន្ថែមសរុបរបស់ប្រព័ន្ធខ្សែច្រវាក់តម្លៃស្រូវអង្ករនិង ប្រាក់ចំណេញរបស់កសិករសម្រាប់ការផលិតអង្ករ ១ តោន**




ប្រភព៖ ការគណនារបស់ក្រុមអ្នកស្រាវជ្រាវ

| ចំនាំ: | WS: រដូវវស្សា | NF: មិនក្រអូប | OM: មានម៉ាស៊ីន | 1T: 1-តោន | UM: ទីផ្សារក្នុងស្រុក |
|---|---|---|---|---|---|
| | DS: រដូវប្រាំង | F: ក្រអូប | RM: ជួលម៉ាស៊ីន | 10T: 10-តោន | EX: ទីផ្សារនាំចេញ |
| | EWS: ដើមរដូវវស្សា | PF:ក្រអូបប្រកាន់រដូវ | | | |

ក្រាបទី១២: បង្ហាញពីទំនាក់ទំនងរវាងតម្លៃបន្ថែមក្នុងការផលិតអង្ករពីដី ១ ហិកតា ដែលបង្កើតដោយប្រព័ន្ធខ្សែច្រវាក់តម្លៃស្រូវអង្ករនីមួយៗ និងប្រាក់ចំណេញរបស់កសិករសម្រាប់ការចូលរួមក្នុងការផលិតអង្ករពីដី ១ ហិកតា។ ប្រព័ន្ធខ្សែច្រវាក់តម្លៃស្រូវអង្ករដែលបង្កើតបានតម្លៃបន្ថែមខ្ពស់ មិនប្រាកដថានឹងអាចធ្វើឱ្យកសិករអាចទទួលបានប្រាក់ចំណេះច្រើនរីឯប្រព័ន្ធខ្សែច្រវាក់តម្លៃស្រូវអង្ករដែលបង្កើតតម្លៃបន្ថែមមិនបានច្រើន បែរជាអាចធ្វើឱ្យកសិករទទួលបានប្រាក់ចំណេញច្រើនពីដី ១ ហិកតា។

### ក្រាបទី១២: តម្លៃបន្ថែមសរុបរបស់ប្រព័ន្ធខ្សែច្រវាក់តម្លៃស្រូវអង្ករ និងប្រាក់ចំណេញរបស់កសិករពីដី ១ ហិកតា




ប្រភព៖ ការគណនារបស់ក្រុមអ្នកស្រាវជ្រាវ

| ចំនាំ: | WS: រដូវវស្សា | NF: មិនក្រអូប | OM: មានម៉ាស៊ីន | 1T: 1-តោន | UM: ទីផ្សារក្នុងស្រុក |
|---|---|---|---|---|---|
| | DS: រដូវប្រាំង | F: ក្រអូប | RM: ជួលម៉ាស៊ីន | 10T: 10-តោន | EX: ទីផ្សារនាំចេញ |
| | EWS: ដើមរដូវវស្សា | PF:ក្រអូបប្រកាន់រដូវ | | | |

### កាបទី១៣: តម្លៃបន្ថែម និងប្រាក់ចំណូលរបស់កសិករតាមប្រភេទស្រូវអង្ករ




ប្រភព៖ ការគណនារបស់ក្រុមអ្នកស្រាវជ្រាវ

### ក្រាបទី១៤: តម្លៃបន្ថែមសរុប និងប្រាក់ចំណូលរបស់កសិករពីដី ១ហិកតា តាមប្រភេទស្រូវអង្ករ




ប្រភព៖ ការគណនារបស់ក្រុមអ្នកស្រាវជ្រាវ

### ២.៣.៣. ទិន្នផលមូលធន

ក្រាបទី១៥: បង្ហាញពីទិន្នផលមូលធន សម្រាប់ប្រព័ន្ធស្រូវអង្ករនីមួយៗដែលមានទំហំពី ២៦% ទៅ ៨០% ដោយមិនគិតពីថ្លៃឈ្នួលដី។ ប្រសិនបើយើងបូកបញ្ចូលថ្លៃឈ្នួលដីនោះទិន្នផលមូលធននឹងថយចុះហើយដោយមានទំហំពី ១៥% ទៅ ៦២% ប៉ុណ្ណោះ។

**ក្រាបទី១៥: ផលទទួលបានពីមូលធនសម្រាប់ប្រព័ន្ធខ្សែច្រវាក់តម្លៃស្រូវអង្ករនីមួយៗ (%)**




ប្រភព៖ការគណនារបស់ក្រុមអ្នកស្រាវជ្រាវ

| ចំនាំ: | | | | |
|---|---|---|---|---|
| WS: រដូវវស្សា | NF: មិនក្រអូប | OM: មានម៉ាស៊ីន | 1T: 1-តោន | UM: ទីផ្សារក្នុងស្រុក |
| DS: រដូវប្រាំង | F: ក្រអូប | RM: ជួលម៉ាស៊ីន | 10T: 10-តោន | EX: ទីផ្សារនាំចេញ |
| EWS: ដើមរដូវវស្សា | PF:ក្រអូបប្រកាន់រដូវ | | | |

### ២.៤. ឥទ្ធិពលរបស់កត្តាផ្សេងៗទៅលើផលទទួលបានពីការវិនិយោគ

ក្រាបទី១៦: បង្ហាញពីការវិភាគភាពប្រែប្រួលរបស់ប្រព័ន្ធទី៧៖ ស្រូវវស្សាក្រអូបកសិករមានរោងម៉ាស៊ីនកិនស្រូវមានសមត្ថភាពកិន ១០ តោន សម្រាប់ទីផ្សារនាំចេញ។ យើងធ្វើការវិភាគពីប្រព័ន្ធមួយនេះ ដោយសារប្រព័ន្ធមួយនេះបង្កើតតម្លៃបន្ថែមបានខ្ពស់ជាងគេ។ ការវិភាគបញ្ជាក់ថាភាពចំណេញតិចតួច និងភាពប្រកួតប្រជែងទន់ខ្សោយរបស់វិស័យស្រូវអង្ករគឺបណ្តាលមកពី ថ្លៃដីនិងថ្លៃប្រេងឥន្ធនៈដែលមានកម្រិតខ្ពស់ រីឯការបង្កើនការប្រើប្រាស់លទ្ធភាពកិនស្រូវរបស់រោងម៉ាស៊ីនកិនស្រូវ គឺជាកត្តាដែលធ្វើឱ្យរោងម៉ាស៊ីនកិនស្រូវទទួលបានផលប្រយោជន៍ច្រើន។ បើមើលពីខ្សែច្រវាក់តម្លៃស្រូវអង្ករ រួមអត្រាការប្រាក់មានឥទ្ធិពលទៅលើផលទទួលបានពីការវិនិយោគតិចជាងថ្លៃអគ្គិសនីនិងអត្រាការប្រាក់សម្រាប់កសិករ។

**ក្រាបទី១៦: ឥទ្ធិពលរបស់កត្តាសំខាន់មួយចំនួនទៅផលទទួលបានពីការវិនិយោគរបស់ប្រព័ន្ធទី៧៖ ស្រូវវស្សាក្រអូបកសិករមានម៉ាស៊ីនរោងម៉ាស៊ីនកិនស្រូវមានសមត្ថភាពកិន ១០តោន សម្រាប់ទីផ្សារនាំចេញ**




ប្រភព៖ ការគណនារបស់ក្រុមអ្នកស្រាវជ្រាវ

## ២.៥. ភាពចំណេញរបស់រោងម៉ាស៊ីនកិនស្រូវ

ការវិភាគរបស់យើង រកឃើញថា រោងម៉ាស៊ីនតូចដែលមានសមត្ថភាព កិនស្រូវ ១តោន ធ្វើបានល្អជាងរោងម៉ាស៊ីនធំដែលមានសមត្ថភាព កិន ១០តោន។ ទោះជារោងម៉ាស៊ីនតូចធ្វើបានល្អជាងរោងម៉ាស៊ីនធំយើងមិនបានរកឃើញថាមានរោងម៉ាស៊ីនតូចណាមួយដែលអាចលក់អង្ករទៅទីផ្សារនាំចេញបានខណៈដែលប្រព័ន្ធខ្សែច្រវាក់តម្លៃស្រូវអង្ករដែលល្អជាងគេគឺជាប្រព័ន្ធដែលមានរោងម៉ាស៊ីនធំនិងលក់អង្ករទៅទីផ្សារនាំចេញ។

ការវិភាគពីភាពប្រែប្រួលក្នុងនៅក្រាបទី ១៧ និងក្រាបទី ១៨ បង្ហាញថាភាពចំណេញរបស់រោងម៉ាស៊ីនកិនស្រូវគឺមានទំនាក់ទំនងខ្លាំងជាមួយនឹងការប្រើប្រាស់លទ្ធភាពកិនស្រូវឱ្យបានច្រើន។ ឧបមាថាមានរោងម៉ាស៊ីនកិនស្រូវទំហំ ១០ តោន ដែលអាចកិនស្រូវបាន ៤០០០០ តោន ក្នុង១ឆ្នាំ។ បើរោងម៉ាស៊ីននោះកិនស្រូវបានតែ ១២០០០ តោន ក្នុង ១ ឆ្នាំនោះរោងម៉ាស៊ីននេះនឹងមិនអាចរកប្រាក់ចំណូលបានទេ (ទិន្នផលមូលធនស្មើនឹង០)។

ការវិភាគពីភាពប្រែប្រួលពីឥទ្ធិពលនៃការប្រើប្រាស់សមត្ថភាពកិនស្រូវ និងអត្រាការប្រាក់ដែលរោងម៉ាស៊ីនទទួលបាន ទៅលើភាពចំណេញរបស់រោងម៉ាស៊ីនកិនស្រូវ បានបង្ហាញថាកម្រិតនៃការប្រើប្រាស់សមត្ថភាពកិនស្រូវ មានទម្ងន់ធ្ងន់ជាងអត្រាការប្រាក់។ អាចនិយាយថាបញ្ហាធំរបស់រោងម៉ាស៊ីនកិនស្រូវគឺស្ថិតលើកម្រិតនៃការប្រើប្រាស់សមត្ថភាពកិនស្រូវជាជាងអត្រាការប្រាក់។ ទោះជាអត្រាការប្រាក់ស្ថិតនៅកម្រិត ១៦% ក៏រោងម៉ាស៊ីនអាចទទួលយកបានដែរ បើសិនជារោងម៉ាស៊ីនទទួលបានការបញ្ជាទិញខ្ពស់ដែលអាចឱ្យរោងម៉ាស៊ីនកិនស្រូវបានច្រើន។ ទោះជាយ៉ាងណាក៏ដោយសមត្ថភាពរបស់រោងម៉ាស៊ីនក្នុងរកបានទីផ្សារ ជាពិសេសទីផ្សារនាំចេញនៅតែជាបញ្ហាចំបងសម្រាប់ដំណើរការនៃអាជីវកម្មរបស់ពួកគាត់ដោយសារតែការនាំចេញទៅទៅផ្សារអឺរ៉ុបនៅមានកម្រិត។

តារាងទី១: បង្ហាញពីទំនាក់ទំនងនៃកម្រិតប្រាក់ចំណេញដែលរោងម៉ាស៊ីនទទួលបាន ពីការកិនស្រូវវស្សាក្រអូប និងនាំអង្ករទៅទីផ្សារ នាំចេញទៅនឹងថ្លៃស្រូវដែលទិញចូលយកមកកិន និងថ្លៃលក់អង្ករទៅផ្សារនាំចេញ។ ប្រសិនបើកត្តាផ្សេងទៀត មិនមានការប្រែប្រួល ហើយថ្លៃអង្ករក្រអូបរដូវវស្សានៅ ៦៨៨ ដុល្លារ ក្នុង ១ តោន រោង ម៉ាស៊ីនដែលមានសមត្ថភាព ១០ តោន អាចទិញស្រូវបានក្នុងតម្លៃ ១៣០០ រៀល ក្នុង ១ គីឡូក្រាម (កើន ១០០ រៀល) ហើយអាច រក្សាផលទទួលបានពីមូលធននៅកម្រិត ៣.៩%។

**ក្រាបទី១៧: ទិន្នផលមូលធនរបស់រោងម៉ាស៊ីន ១០ តោន ទៅតាមបរិមាណកិនស្រូវ**




ប្រភព៖ ការគណនារបស់ក្រុមអ្នកស្រាវជ្រាវ

**ក្រាបទី១៨: ប្រាក់ចំណេញរបស់រោងម៉ាស៊ីន ១០តោន ទៅតាមកត្តាមួយចំនួន**




ប្រភព៖ ការគណនារបស់ក្រុមអ្នកស្រាវជ្រាវ

តារាងទី១ : ទំនាក់ទំនងរវាងលទ្ធភាពចំណេញរបស់រោងម៉ាស៊ីនកិនស្រូវនឹងថ្លៃស្រូវដែលទិញចូល និង ថ្លៃអង្ករដែលលក់ចេញសម្រាប់ប្រព័ន្ធទី៨៖ រដូវវស្សាក្រអូបប្រកាន់រដូវជួលម៉ាស៊ីន ១០ តោន ទីផ្សារនាំចេញ

| ថ្លៃស្រូវ ទិញចូល រៀល/គីឡូ | ថ្លៃអង្ករលក់ចេញដុល្លារ និង រៀល/តោន | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | 442 | 492 | 541 | 590 | 639 | 688 | 737 | 787 | 836 |
| | 1 800 000 | 2 000 000 | 2 200 000 | 2 400 000 | 2 600 000 | 2 800 000 | 3 000 000 | 3 200 000 | 3 400 000 |
| 400 | 75.4% | 93.7% | 111.9% | 130.2% | 148.4% | 166.6% | 184.8% | 202.9% | 221.0% |
| 500 | 49.3% | 64.9% | 80.5% | 96.0% | 111.5% | 127.1% | 142.6% | 158.0% | 173.5% |
| 600 | 30.0% | 43.6% | 57.1% | 70.7% | 84.2% | 97.7% | 111.3% | 124.8% | 138.3% |
| 700 | 15.1% | 27.1% | 39.1% | 51.2% | 63.1% | 75.1% | 87.1% | 99.1% | 111.0% |
| 800 | 3.3% | 14.1% | 24.9% | 35.6% | 46.4% | 57.2% | 67.9% | 78.7% | 89.4% |
| 900 | -6.4% | 3.4% | 13.2% | 23.0% | 32.8% | 42.5% | 52.3% | 62.1% | 71.8% |
| 1 000 | -14.3% | -5.4% | 3.6% | 12.5% | 21.5% | 30.4% | 39.3% | 48.3% | 57.2% |
| 1 100 | -21.1% | -12.8% | -4.6% | 3.7% | 11.9% | 20.2% | 28.4% | 36.6% | 44.9% |
| 1 200 | -26.8% | -19.2% | -11.5% | -3.9% | 3.8% | 11.4% | 19.1% | 26.7% | 34.3% |
| 1 300 | -31.8% | -24.6% | -17.5% | -10.4% | -3.3% | 3.9% | 11.0% | 18.1% | 25.2% |
| 1 400 | -36.1% | -29.4% | -22.8% | -16.1% | -9.4% | -2.7% | 3.9% | 10.6% | 17.3% |
| 1 500 | -39.9% | -33.7% | -27.4% | -21.1% | -14.8% | -8.5% | -2.3% | 4.0% | 10.3% |
| 1 600 | -43.3% | -37.4% | -31.5% | -25.5% | -19.6% | -13.7% | -7.8% | -1.8% | 4.1% |
| 1 700 | -46.4% | -40.7% | -35.1% | -29.5% | -23.9% | -18.3% | -12.7% | -7.1% | -1.5% |
| 1 800 | -49.1% | -43.7% | -38.4% | -33.1% | -27.8% | -22.4% | -17.1% | -11.8% | -6.5% |
| 1 900 | -51.5% | -46.5% | -41.4% | -36.3% | -31.2% | -26.2% | -21.1% | -16.0% | -11.0% |
| 2 000 | -53.8% | -48.9% | -44.1% | -39.2% | -34.4% | -29.6% | -24.7% | -19.9% | -15.1% |

ប្រភព៖ការគណនារបស់ក្រុមអ្នកស្រាវជ្រាវ

ចំនាំ: បរិមាណស្រូវដែលនឹងត្រូវកិន: ២៥០០០តោនថ្លៃស្រូវ: ១២០០រៀល / គីឡូថ្លៃអង្ករ: ៦៦៨ ដុល្លារ / តោន

តារាងទី២ : ទំនាក់ទំនងរវាងលទ្ធភាពចំណេញរបស់រោងម៉ាស៊ីនកិនស្រូវនឹងថ្លៃស្រូវដែលទិញចូល និង ថ្លៃអង្ករដែលលក់ចេញសម្រាប់ប្រព័ន្ធទី៥៖ រដូវប្រាំងមិនក្រអូបមានម៉ាស៊ីន ១០ តោន ទីផ្សារនាំចេញ

| ថ្លៃស្រូវ ទិញចូល រៀល/គីឡូ | ថ្លៃអង្ករលក់ចេញដុល្លារ និង រៀល/តោន | | | | | | | |
|---|---|---|---|---|---|---|---|---|
| | 300 | 350 | 400 | 450 | 500 | 550 | 600 | 650 |
| | 1 220 400 | 1 423 800 | 1 627 200 | 1 830 600 | 2 034 000 | 2 237 400 | 2 440 800 | 2 644 200 |
| 400 | 22% | 40% | 59% | 77% | 96% | 114% | 133% | 151% |
| 500 | 4% | 20% | 36% | 52% | 68% | 84% | 100% | 116% |
| 600 | -9% | 5% | 19% | 33% | 47% | 61% | 75% | 89% |
| 700 | -19% | -6% | 6% | 19% | 31% | 43% | 56% | 68% |
| 800 | -27% | -16% | -4% | 7% | 18% | 29% | 40% | 51% |
| 900 | -33% | -23% | -13% | -3% | 7% | 17% | 27% | 38% |
| 1 000 | -39% | -30% | -20% | -11% | -2% | 8% | 17% | 26% |
| 1 100 | -44% | -35% | -26% | -18% | -9% | -1% | 8% | 17% |
| 1 200 | -48% | -40% | -32% | -24% | -16% | -8% | 0% | 8% |
| 1 300 | -51% | -44% | -36% | -29% | -21% | -14% | -6% | 1% |
| 1 400 | -54% | -47% | -40% | -33% | -26% | -19% | -12% | -5% |
| 1 500 | -57% | -50% | -44% | -37% | -31% | -24% | -17% | -11% |
| 1 600 | -59% | -53% | -47% | -41% | -34% | -28% | -22% | -16% |
| 1 700 | -61% | -55% | -50% | -44% | -38% | -32% | -26% | -20% |

ប្រភព៖ការគណនារបស់ក្រុមអ្នកស្រាវជ្រាវ

ចំនាំ: បរិមាណស្រូវដែលនឹងត្រូវកិន: 25,000 តោនថ្លៃស្រូវ: ៨០០រៀល / គីឡូថ្លៃអង្ករ: ៤៥០ ដុល្លារ / តោន

# ៣. សរុបសេចក្ដី និងអនុសាសន៍

យោងទៅតាមស្ថានភាពថ្លៃជាតុចូល និងជាតុចេញបច្ចុប្បន្នជាមធ្យមប្រព័ន្ធខ្សែច្រវាក់តម្លៃស្រូវអង្ករទាំង ១៣ ដែលត្រូវបានវិភាគ អាចទទួលបានប្រាក់ចំណេញ និងដំណើរការបានសម្រាប់ភ្នាក់ងារគ្រប់រូប។ យើងសង្កេតឃើញថា ប្រព័ន្ធខ្សែច្រវាក់តម្លៃស្រូវមិនក្រអូបរដូវប្រាំង និងដើមរដូវវស្សាដែលស្រូវសើមភាគច្រើនត្រូវបាននាំចេញទៅប្រទេស វៀតណាមទទួលបានផលចំណេញតិចតួចជាងប្រព័ន្ធស្រូវក្រអូប និង ប្រព័ន្ធស្រូវរដូវវស្សា។ កសិករគឺជាភ្នាក់ងារដែលទទួលបានតម្លៃបន្ថែម ខ្ពស់ជាងគេ ក្នុងចំណោមភ្នាក់ងារទាំងអស់ បន្ទាប់មកគឺរោងម៉ាស៊ីន កិនស្រូវរីឯឈ្មួញលក់អង្ករ និងឈ្មួញប្រមូលទិញស្រូវស្ថិតនៅ លេខ ៣ និងលេខ ៤ នៅគ្រប់ប្រព័ន្ធខ្សែច្រវាក់តម្លៃស្រូវអង្ករ។

ការវិភាគរបស់យើង បានបញ្ជាក់ថាប្រព័ន្ធដែលធ្វើបានល្អជាងគេគឺប្រព័ន្ធស្រូវអង្ករក្រអូបរដូវវស្សាឬរដូវប្រាំង ដែលកសិករមានម៉ាស៊ីន។ ប្រព័ន្ធទាំងនេះក៏ត្រូវបានដំណើរការដោយរោងម៉ាស៊ីនធំ (១០តោន ក្នុង ១ ម៉ោង) ដែលលក់អង្ករក្រអូបទៅទីផ្សារនាំចេញ។ យើងក៏សង្កេត ឃើញថា ប្រព័ន្ធស្រូវអង្ករចំនួន ២ ដែលយើងមានការព្រួយបារម្ភពី ផលប៉ះពាល់លើសុខភាព និងបរិស្ថានខ្ពស់គឺប្រព័ន្ធស្រូវមិនក្រអូប ដើមរដូវវស្សា និងរដូវប្រាំងដែលមានការចំណាយលើជី និងថ្នាំគីមីខ្ពស់។ ការប្រើប្រាស់ជី និងថ្នាំគីមីច្រើនពេក អាចបង្កជាផលប៉ះពាល់ លើសុខភាពរបស់កសិករអ្នកបរិភោគ និងបរិស្ថាន។

ជាមធ្យមតម្លៃបន្ថែមដែលបង្កើតពីការផលិតអង្ករ ១តោន មានទំហំ ២៦៦ ដុល្លារ តម្លៃបន្ថែមដែលបង្កើតពីដីស្រែ ១ ហិកតា មានទំហំ ៤៤៤ ដុល្លារ។ ការធ្វើស្រែជាមធ្យមទទួលបាន ៥០ នៃតម្លៃបន្ថែមសរុប និងការវិភាគបង្ហាញថាបើតម្លៃបន្ថែមបង្កើតបានកាន់តែខ្ពស់ នោះភាគរយដែលកសិករទទួលបានក៏កាន់តែខ្ពស់។ ក្នុងតម្លៃបន្ថែមសរុបពេលនេះរោងម៉ាស៊ីនទទួលបាន ២៣ ឈ្មួញលក់អង្ករទទួល បាន ១៨% និងឈ្មួញប្រមូលទិញស្រូវទទួលបាន ៩%។ ប៉ុន្តែនៅ ពេលបានឃើញពីតួលេខទាំងនេះអ្នកអានគួរសម្គាល់ថាការវិភាគមិនបានរាប់បញ្ចូល ១) ថ្លៃឱកាសនៃពលកម្មគ្រួសារ ២) ថ្លៃឱកាសនៃ ដីស្រែ នឹង ៣) ផលប៉ះពាល់ផ្សេងៗ (ផលប៉ះពាល់បរិស្ថាន ឬ ការធ្លាក់ចុះជីវជាតិដី)។

ជាការគិតខាងគោលនយោបាយរដ្ឋាភិបាលគួរបន្តការគាំទ្រលើវិស័យស្រូវអង្ករ ដោយសារវិស័យនេះបង្កើតតម្លៃបន្ថែមខ្ពស់សម្រាប់កសិករ។ ការធានាឱ្យបានការប្រើប្រាស់សមត្ថភាពកិនស្រូវយ៉ាងតិច ៣០ នៃ សមត្ថភាពសរុបគឺជាកត្តាចំបងសម្រាប់ភាពចំណេញរបស់រោងម៉ាស៊ីន និងភាពប្រកួតប្រជែងរបស់ខ្សែច្រវាក់តម្លៃផលិតកម្ម។

ការចំណាយលើថាមពល គឺជាកត្តាសំខាន់ទី ២ សម្រាប់ធានាឱ្យបានភាពចំណេញរបស់រោងម៉ាស៊ីនកិនស្រូវ។

- បង្កើនយន្តការដែលអាចកាត់បន្ថយថ្លៃជី និងថ្នាំកសិកម្ម និងពូជស្រូវជាមួយនឹងសកម្មភាពផ្សព្វផ្សាយកសិកម្មដែលផ្ដោតទៅលើការប្រើប្រាស់ជី និងថ្នាំគីមីឱ្យមានប្រសិទ្ធភាពខាងចំណាយ។
- បន្តបង្កើនការផ្ដល់ប្រាក់កម្ចីឱ្យរោងម៉ាស៊ីន និងធ្វើឱ្យប្រសើរឡើងនូវការផ្គត់ផ្គង់អគ្គិសនីដែលមានតម្លៃទាន។
- ការធ្លាក់ចុះថ្លៃអង្ករនៅទីផ្សារអន្តរជាតិរហូតមកដល់ ខែ មិថុនា ឆ្នាំ ២០១៧ បង្ហាញពីការប្រកួតប្រជែងយ៉ាងខ្លាំងនៅទីផ្សារអន្តរជាតិសូម្បីតែចំពោះអង្ករក្រអូបដែលបានតម្លៃខ្ពស់។ ជាមួយនឹងហានិភ័យនៃការបាត់បង់ការអនុគ្រោះពន្ធក្នុងការនាំចេញទៅកាន់ទីផ្សារអឺរ៉ុប ការធ្វើពិពិធកម្មទីផ្សារនាំចេញគឺជាបញ្ហាប្រឈម និងកត្តាចំបងសម្រាប់វិស័យស្រូវអង្កររបស់កម្ពុជា។

**ការសង្កេតលក្ខណៈសេដ្ឋកិច្ចនៃវិស័យស្រូវអង្កររបស់ប្រទេសកម្ពុជា**

ការសង្កេតលក្ខណៈសេដ្ឋកិច្ចនៃវិស័យស្រូវអង្កររបស់ប្រទេសកម្ពុជាគឺជាយន្តការតាមដាន ដែលប្រើប្រាស់ជាកម្រងពត៌មានសម្រាប់អ្នករៀបរៀងគោលនយោយបាយ និងភាគីពាក់ព័ន្ធដើម្បីវិភាគសុខភាព និងភាពប្រកួតប្រជែង នៃវិស័យស្រូវអង្កររបស់ប្រទេសកម្ពុជា និងតាមដានការបែងចែកតម្លៃបន្ថែម និងផលប្រយោជន៍បែបសេដ្ឋកិច្ច និងសង្គមរបស់វិស័យស្រូវអង្ករ។

**ព្រឹត្តិប័ត្រការសង្កេតលក្ខណៈសេដ្ឋកិច្ច នៃវិស័យស្រូវអង្កររបស់ប្រទេសកម្ពុជា៖**

សមទ្ធិផលរបស់ការសង្កេតលក្ខណៈសេដ្ឋកិច្ចនៃវិស័យស្រូវអង្កររបស់ប្រទេសកម្ពុជាគឺជាការរៀបរៀងព្រឹត្តិប័ត្រប្រចាំឆមាសចំនួន ២ ដែលវិភាគ និងផ្ដល់របាយការណ៍ពីការបែងចែកនៃតម្លៃបន្ថែមក្នុងវិស័យស្រូវអង្កររបស់កម្ពុជាសម្រាប់ស្រូវអង្កររដូវវស្សា និងស្រូវអង្កររដូវប្រាំង។ ព្រឹត្តិប័ត្រនីមួយៗគឺយោងទៅតាមខ្ទង់ចំណូលចំណាយជាមធ្យមរបស់ភ្នាក់ងារផ្សេងៗនៅក្នុងខ្សែច្រវាក់តម្លៃផលិតកម្ម និងបង្ហាញពីចំណាយលម្អិតរបស់ភ្នាក់ងារនីមួយៗ ការបែងចែកតម្លៃបន្ថែម និងសូចនាករសំខាន់ៗមួយចំនួន។ ការវិភាគពីឥទ្ធិពល នៃកត្តាសំខាន់មួយចំនួនទៅលើភាពចំណេញ និងការបែងចែកប្រាក់ចំណេញក៏ត្រូវបានបញ្ចូលទៅក្នុងព្រឹត្តិប័ត្រនេះសម្រាប់អ្នកសម្រេចលើគោលនយោបាយ ផ្ដោតលើយន្តការដែលបង្កើតផលប្រយោជន៍ខ្ពស់។

**អភិបាលកិច្ចលើការសង្កេតលក្ខណៈសេដ្ឋកិច្ចនៃវិស័យស្រូវអង្កររបស់ប្រទេសកម្ពុជា៖**

ការសង្កេតលក្ខណៈសេដ្ឋកិច្ចនៃវិស័យស្រូវអង្កររបស់ប្រទេសកម្ពុជាស្ថិតក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលនៅក្រោមការទទួលខុសត្រូវរបស់គណៈកម្មាធិការមួយមានតួនាទីជាស្ថាប័នបញ្ជាទៅលើអង្គភាពបច្ចេកទេសដែលមានតួនាទីលើការអនុវត្តលើការងារប្រមូលទិន្នន័យ និងវិភាគ។

គណៈកម្មាធិការមានការចូលរួមពីតំណាងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិដែលជាប្រធានតំណាងក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទក្រសួងពាណិជ្ជកម្ម និងសហព័ន្ធស្រូវអង្ករកម្ពុជា។ ស្ថាប័នទាំងនេះក៏មានតួនាទីជួយសម្រួលលើការប្រមូលទិន្នន័យ និងពត៌មាន និងចូលរួមបញ្ជាក់ទិន្នន័យ។ បន្ទាប់ពីគម្រោងជំរុញការធ្វើពាណិជ្ជកម្មអង្ករកម្ពុជា ការសង្កេតលក្ខណៈសេដ្ឋកិច្ចនៃវិស័យស្រូវអង្កររបស់ប្រទេសកម្ពុជាត្រូវបានមើលឃើញថានឹងត្រូវបានបញ្ចូលទៅក្រោមក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ។

អង្គភាពបច្ចេកទេសសម្រាប់ការអនុវត្តលើកទី ១ មានការចូលរួមពីជំនាញការអន្តរជាតិ ១ រូប ពីមជ្ឈមណ្ឌលស្រាវជាវអន្តរជាតិបារាំងសម្រាប់ការអភិវឌ្ឍកសិកម្ម (CIRAD) និងជំនាញការជាតិ ២ រូប ពីមជ្ឈមណ្ឌលសិក្សាគោលនយោបាយ។ គម្រោងជំរុញការធ្វើពាណិជ្ជកម្មអង្ករកម្ពុជារបស់ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិដែលផ្ដល់ជំនួយដោយភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD) បានជួយការរៀបរៀងព្រឹត្តិប័ត្រនេះទាំងបច្ចេកទេសទាំងថវិកា។